CITY OF LONGBEACH **PRESS RELEASE**

**សេចក្តីប្រកាសព័ត៌មាន**

ថ្ងៃទី ១០ ខែកក្កដាឆ្នាំ ២០២០

ទំនាក់ទំនង៖ Kate Kuykendall, មន្ត្រីកិច្ចការសាធារណៈ, អាកាសយានដ្ឋានឡុងប៊ិច, 562.965.9116,
kate.kuykendall@longbeach.gov

សម្រាប់សេចក្តីប្រកាសជាបន្ទាន់

# អាកាសយានដ្ឋានឡុងប៊ិចរៀបចំនឹងបែងចែកជើងហោះហើរតាមលេខរាងក្នុងបញ្ជីរង់ចាំ

ទីក្រុងឡុងប៊ិច, រដ្ឋកាលីហ្វ័រញ៉ា - ជាការឆ្លើយតបទៅនឹងសេចក្តីប្រកាសថ្មីៗរបស់ក្រុមហ៊ុន JetBlue ដែលថានឹងដកហូតជើងហោះហើរដែលនៅសល់នៅខែតុលាអាកាសយានដ្ឋានឡុងប៊ិចនឹងចាប់ផ្តើមដំណើរការជាផ្លូវការនៃការបែងចែកជើងហោះហើរអស់ទាំងនោះតាមរយៈបញ្ជីរង់ចាំដែលបានបង្កើតហើយដែលរួមមានក្រុមហ៊ុនអាកាសចរណ៍ធំៗចំនួន ៣ រួចហើយ។ ក្រុមហ៊ុនអាកាសចរណ៍ដែលមានវិញ្ញាបនបត្រផ្សេងទៀតក៏អាចស្នើសុំឲ្យបញ្ចូលទៅក្នុងបញ្ជីរង់ចាំដើម្បីចូលរួមក្នុងដំណើរការបែងចែកជើងហោះហើរ។

លោកអភិបាលក្រុង Robert Garcia បានមានប្រសាសន៍ថា "នៅអាកាសយានដ្ឋានឡុងប៊ិចយើងមានបញ្ជីរង់ចាំដែលមានក្រុមហ៊ុនអាកាសចរណ៍ជាច្រើនហើយតម្រូវការនៃជើងហោះហើរនៅតែមានដដែល។ នៅពេលការធ្វើដំណើរតាមផ្លូវអាកាសបានធូរស្បើយពីវិបត្តិ COVID-19 យើងទន្ទឹងរង់ចាំការងើបឡើងវិញយ៉ាងខ្លាំង។"

ចំនួនសរុបនៃជើងហោះហើរអចិន្ត្រៃយ៍ចំនួន ១៧ នឹងមានឲ្យប្រើប្រាស់ក្នុងពេលឆាប់ៗនេះ។ អាកាសយានដ្ឋានផ្តល់ជូននូវជើងហោះហើរចំនួន ៤១ ជាអចិន្ត្រៃយ៍និងជើងហោះហើរ ១២ បន្ថែមទៀត។ ជើងហោះហើរបន្ថែមមានលក្ខណៈប្លែកពីគេដោយព្រោះជើងហោះហើរទាំងនេះអាចទទួលការវាយតម្លៃប្រចាំឆ្នាំអំពីសំលេងរំខានសរុបរបស់អាកាសយានដ្ឋាន។

លោក Cynthia Guidry នាយកអាកាសយានដ្ឋានឡុងប៊ិចបាននិយាយថា "អ្នកដំណើររបស់យើងពេញចិត្តនឹងបទពិសោធន៍នៃការធ្វើដំណើរបែបវរជនដែលយើងផ្តល់ជូនដោយមានទីធ្លាខាងក្រៅនិងបរិយាកាសដែលគ្មានការខ្វាយខ្វល់។ យើងមានជំហរល្អក្នុងការបន្តជាអាកាសយានដ្ឋានជម្រើសសម្រាប់រដ្ឋកាលីហ្វ័រញ៉ាភាគខាងត្បូងហើយយើងទន្ទឹងរង់ចាំទទួលដំណឹងពីក្រុមហ៊ុនអាកាសចរណ៍អំពីចំណាប់អារម្មណ៍របស់ពួកគេចំពោះជើងហោះហើរដែលទំនេររបស់យើង។"

ក្រុមហ៊ុនអាកាសចរណ៍ទាំងបីដែលស្ថិតនៅក្នុងបញ្ជីរង់ចាំសម្រាប់ជើងហោះហើរអចិន្ត្រៃយ៍តាមលំដាប់គឺក្រុមហ៊ុនអាកាសចរណ៍ Southwest ក្រុមហ៊ុនអាកាសចរណ៍ Hawaiian និងក្រុមហ៊ុនអាកាសចរណ៍ Delta។ ជើងហោះហើរមួយនឹងត្រូវផ្តល់ជូនដល់ក្រុមហ៊ុនអាកាសចរណ៍នីមួយៗបន្ថែមពីលើអ្នកចូលរួមថ្មីតាមលំដាប់រហូតដល់រាល់ជើងហោះហើរបានបែងចែកអស់។ នៅពេលដែលមានជើងហោះហើរទំនេរ អាកាសយានដ្ឋានមានរយៈពេល ៣០ ថ្ងៃដើម្បីបែងចែកជើងហោះហើរទាំងនោះដល់ក្រុមហ៊ុនអាកាសចរណ៍ដែលបានធ្វើការស្នើសុំ។

ជើងហោះហើរចំនួន ៥៣ របស់អាកាសយានដ្ឋាននៅពេលបច្ចុប្បន្ននេះបានត្រូវបែងចែកដូចខាងក្រោម (ជើងហោះហើរចំនួន ១៧ របស់ក្រុមហ៊ុន JetBlue នឹងទំនេរឲ្យប្រើប្រាស់នាពេលឆាប់ៗនេះ)៖

| ក្រុមហ៊ុនអាកាសចរណ៍ | ជើងហោះហើរអចិន្ត្រៃយ៍ | ជើងហោះហើរបន្ថែម | ជើងហោះហើរសរុប |
| --- | --- | --- | --- |
| American Airlines | 3 | 0 | 3 |
| Delta Air Lines | 9 | 3 | 12 |
| FedEx | 1 | 0 | 1 |

| | | | |
|---|---|---|---|
| Hawaiian Airlines | 2 | 0 | 2 |
| JetBlue Airways | 17 | 0 | 17 |
| Southwest Airlines | 8 | 9 | 17 |
| UPS | 1 | 0 | 1 |
| **ចំនួនសរុប** | 41 | 12 | 53 |

ដែលមានទីតាំងស្ថិតនៅជិតព្រំប្រទល់រវាងខោនធី Los Angeles និងខោនធី Orange អាកាសយានដ្ឋានឡុងប៊ិស្ថិតនៅជិតកន្លែងទាក់ទាញសំខាន់ៗជាច្រើននៅរដ្ឋកាលីហ្វ័រញ៉ាភាគខាងត្បូង។

**អំពីទីក្រុងឡុងប៊ិច**

ជាទីលំនៅដ្ឋាននៃប្រជាជនប្រមាណ ៤៨០,០០០ នាក់ទីក្រុងឡុងប៊ិចបានទទួលពានរង្វាន់និងជាទីក្រុងច្នៃប្រឌិតដែលផ្តល់ជូននូវភាពសំបូរបែបនៃពិភពលោកខណៈពេលដែលរក្សាលក្ខណៈបុគ្គលនិងដែលបង្កើតឡើងពីសង្កាត់ផ្សេងៗពីគ្នាដែលបានផ្តុំនៅតាមបណ្តោយឆ្នេរសមុទ្រប៉ាស៊ីហ្វិក។ ក្នុងនាមជាទីក្រុងដែលមានសេវាកម្មពេញលេញទីក្រុងឡុងប៊ិចជាលំនៅដ្ឋានរបស់នាវា Queen Mary, អាងចិញ្ចឹមត្រីនៃមហាសមុទ្រប៉ាស៊ីហ្វិក (Aquarium of the Pacific), សារមន្ទីរនិងរោងកុនជាច្រើន, សាលារៀនដែលត្រូវបានវាយតម្លៃខ្ពស់, អាកាសយានដ្ឋានឡុងប៊ិច, កំពង់ផែឡុងប៊ិច ក៏ដូចជាមន្ទីរផ្សេងៗដែលបានទទួលពានរង្វាន់ជាច្រើនដូចជាមន្ទីរសុខាភិបាល មន្ទីរឧទ្យានការកំសាន្តនិងសមុទ្រ មន្ទីរសេវាកម្មអភិវឌ្ឍន៍ និងមន្ទីរផ្សេងៗទៀត។ ទីក្រុងនេះក៏មានសាកលវិទ្យាល័យនិងមហាវិទ្យាល័យដែលត្រូវបានការគោរពខ្ពស់ ក៏ដូចជាកន្លែងចិញ្ចឹមសត្វជាប្រវត្តិសាស្ត្រចំនួន២ មន្ទីរពេទ្យ៥ ទីតាំង៥សម្រាប់លេងហ្គោល សួន១៧០ ឆ្នេរសមុទ្រជាច្រើនម៉ាយល៍ម៉ា ផ្លូវសម្រាប់ជិះកង់ និងកម្មវិធីជិះកង់ដែលមានការចែករំលែក។

សម្រាប់ព័ត៌មានបន្ថែមអំពីទីក្រុងឡុងប៊ិចសូមចូលទៅកាន់គេហទំព័រ http://longbeach.gov/។ សូមតាមដានទីក្រុងឡុងប៊ិចនៅលើបណ្តាញសង្គមសម្រាប់ព័ត៌មានថ្មីៗនៅលើ ហ្វេសប៊ុក ធ្វីតធ័រ Instagram និង យូធ្យូប។

**អំពីអាកាសយានដ្ឋានឡុងប៊ិច**

បង្កើតឡើងក្នុងឆ្នាំ ១៩២៣ អាកាសយានដ្ឋានឡុងប៊ិច (LGB) ជាព្រលានយន្តហោះចំណាស់ជាងគេនៅរដ្ឋកាលីហ្វ័រញ៉ា។ ចំណតអ្នកដំណើរថ្មីបានបើកក្នុងឆ្នាំ ២០១២ ហើយចាប់តាំងពីពេលនោះមកទទួលបានការកោតសរសើរយ៉ាងខ្លាំងចំពោះការរចនានិងស្ថាបត្យកម្មទំនើប ការទទួលទានអាហារក្នុងស្រុក និងបទពិសោធន៍ធ្វើដំណើរងាយស្រួល។ ក្នុងចំណោមពានរង្វាន់ជាច្រើនអាកាសយានដ្ឋានឡុងប៊ិចត្រូវបានគេដាក់នាមថាជាអាកាសយានដ្ឋានកំពូលទាំង ១០ សំរាប់ការប្រកួតអាកាសយានដ្ឋានខ្នាតតូចល្អបំផុតដោយអ្នកអានកាសែត USA Today ឆ្នាំ ២០២០។ អាកាសយានដ្ឋានឡុងប៊ិចផ្តល់ជូននូវសេវាកម្មមិនឈប់ដល់ទីក្រុងមួយចំនួននៃសហរដ្ឋអាមេរិកខណៈពេលដែលគាំទ្រដល់សហគមន៍អាកាសចរណ៍ទូទៅជាមួយនឹងប្រតិបត្តិការប្រចាំឆ្នាំជាង 300,000។ អាកាសយានដ្ឋាននេះក៏ជាប្រភពនៃសកម្មភាពសេដ្ឋកិច្ចនិងការងារយ៉ាងច្រើនផងដែរដោយអគារអាកាសចរណ៍នៃអាកាសយានដ្ឋានឡុងប៊ិចបានបង្កើតផលប៉ះពាល់សេដ្ឋកិច្ចដល់ $8.6 ពាន់លានដុល្លារនិងគាំទ្រការងារចំនួន 46,000។ អាកាសយានដ្ឋានឡុងប៊ិចគឺជាសហគ្រាសទ្រទ្រង់ខ្លួនឯងនៃទីក្រុងឡុងប៊ិចនិងមិនទទួលបានប្រាក់ពន្ធក្នុងស្រុកទេ។ អាកាសយានដ្ឋានមានមោទនភាពក្នុងការថែរក្សាកេរ្តិ៍ដំណែលជាប្រវត្តិសាស្ត្រដែលត្រូវបានគេគោរពនិងរក្សាប្រតិបត្តិការប្រកបដោយសុវត្ថិភាព និរន្តរភាព និងការទទួលខុសត្រូវផ្នែកបរិស្ថាន។ សូមតាមដានអាកាសយានដ្ឋានឡុងប៊ិចនៅលើប្រពន្ធ័សង្គមហ្វេសប៊ុក Instagram និង ធ្វីតធ័រនៅ @LGBAirport។

សម្រាប់ព័ត៌មានថ្មីៗអំពីជំងឺ COVID-19 រួមទាំងព័ត៌មានលម្អិតអំពីអ្វីដែលទីក្រុងឡុងប៊ិចកំពុងអនុវត្តដើម្បីការពារសុវត្ថិភាពដល់ប្រជាជនសូមមេត្តាចូលទៅកាន់គេហទំព័រ longbeach.gov/COVID19 ហើយតាមដាន @LongBeachCity នៅលើប្រពន្ធ័សង្គមហ្វេសប៊ុក ធ្វីតធ័រ និង Instagram។

###